ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនដំណឹង
# ស្តីពីការពន្យារពេលក្នុងការផ្សព្វផ្សាយរបាយការណ៍ត្រីមាសទី២ ឆ្នាំ២០២០
# របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនទាំងអស់មេត្តាជ្រាបថា៖ របាយការណ៍ត្រីមាសទី២ ឆ្នាំ២០២០ របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក នឹងត្រូវពន្យារពេលក្នុងការផ្តល់នូវរបាយការណ៍នេះ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ដោយសារមូលហេតុដូចខាងក្រោម:

១. ជារបាយការណ៍លើកទី១ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក បន្ទាប់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក បានចុះបញ្ជីជាផ្លូវការនៅលើទីផ្សារមូលបត្រកម្ពុជា។

២. របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០២០ របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដែលបានរៀបចំ និងត្រួតពិនិត្យដោយសវនករឯករាជ្យ Ernst & Young (Cambodia) Ltd. មានភាពស្មុគស្មាញ និងត្រូវការធនធានមនុស្ស និងពេលវេលាច្រើន។

ដោយសារកត្តាខាងលើនេះ ដែលធ្វើឲ្យរាំងស្ទះក្នុងការផ្ញើរបាយការណ៍ត្រីមាសទី២ ឆ្នាំ២០២០ របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ជូនគណៈកម្មការមូលបត្រកម្ពុជា ក៏ដូចជាផ្សព្វផ្សាយជូនវិនិយោគិន និងសាធារណជន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន ទទួលជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៥ កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | អគារលេខ 212 ផ្លូវ 271 សង្កាត់ទូលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា | ទូរស័ព្ទ៖ 023 220 102 | សេវាអតិថិជន៖ 023 / 086 999 911 | ទូរសារ៖ 023 216 362
ប្រអប់សំបុត្រ៖ 2412 | អ៊ីមែល៖ info@prasac.com.kh | គេហទំព័រ៖ www.prasac.com.kh | ចុះបញ្ជីពាណិជ្ជកម្មលេខ៖ 00001157 | គ្រឹះស្ថានឯកជន